ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន
លេខ: ១២ ស.ក.អ/៩៧

ភ្នំពេញ, ថ្ងៃទី២៤ ខែ[illegible] ឆ្នាំ១៩៩៧

## សេចក្តីជូនដំណឹង
## ស្តីពី
## ប័ណ្ណការងារ និងសៀវភៅការងារជនបរទេស

---

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជូនដំណឹងដល់ជនបរទេសទាំងអស់ ដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា យោងតាមមាត្រា ២៦១ នៃច្បាប់ការងារ ដើម្បីប្រកបមុខរបរអ្វីមួយ ឬមកធ្វើការបំរើអោយក្រុមហ៊ុន រោងចក្រ ឬសហគ្រាស ណាមួយជាបណ្តោះអាសន្នត្រូវមានប័ណ្ណការងារ និងសៀវភៅការងារ ដែលចេញអោយដោយ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

សំណុំលិខិតដែលត្រូវបំពេញរួមមាន :

១. ពាក្យសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រិយ៍ ១.០០០៛ ០១ ច្បាប់
២. សេចក្តីថតចម្លងលិខិតឆ្លងដែន ០១ ច្បាប់
៣. ប័ណ្ណស្នាក់នៅត្រឹមត្រូវ ០១ ច្បាប់
៤. លិខិតបញ្ជាក់កាយសម្បទាល្អ និងសុខភាពល្អ ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ០១ច្បាប់
៥. បង់អាករប្រចាំឆ្នាំ ១០០ ដុល្លារអាមេរិក
៦. រូបថតចំពីមុខ ៤ x ៦ ស.ម ០៤ សន្លឹក

អាស្រ័យហេតុនេះ សូមជនបរទេសទាំងអស់ដែលរស់នៅរាជធានីភ្នំពេញ អញ្ជើញទៅធ្វើប័ណ្ណការងារ និងសៀវភៅការងារអោយបានគ្រប់ៗគ្នា នៅនាយកដ្ឋានមុខរបរ និងពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ស្ថិតនៅអាគារលេខ ២៨ វិថីព្រះធម្មលិខិតអ៊ុក អគ្គីកផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំពោះអ្នកនៅតាមខេត្ត-ក្រុងនានាសូមអញ្ជើញទៅធ្វើប័ណ្ណការងារ និងសៀវភៅការងារនៅអធិការដ្ឋាន សង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុងរៀងៗខ្លួន ។

ក្រុមហ៊ុន សហគ្រាសទាំងឡាយណា ដែលទទួលអោយធ្វើការ ឬរក្សាទុកអោយធ្វើការនូវជនបរទេសដែលគ្មានប័ណ្ណការងារ និងសៀវភៅការងារត្រូវទទួលទោសពិន័យទៅតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន រោងចក្រ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះអោយបានរួសរាន់ និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខាន ។

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

"ដើម្បីជ្រាប"

- ក្រសួងព័ត៌មាន "ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយ"
- គ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- បិទផ្សាយ
- កាលប្បវត្តិ និងឯកសារ

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន

ស៊ុយ សែម